

## ឧបសម្ព័ន្ធ "គ"

# តារាងអភិវឌ្ឍកុមារ

## របៀបប្រើតារាងអភិវឌ្ឍកុមារ

កុមារអភិវឌ្ឍនៅក្នុងផ្នែកចំបងមួយចំនួន :- **កាយសម្បទា** (រាងកាយ) **គំនិតបញ្ញា** (ខួរក្បាល) **ការប្រាស្រ័យទាក់ទង** (ការធ្វើសញ្ញា ឬនិយាយ) និង**សង្គម** (ផ្សារភ្ជាប់ខ្លួនទៅមនុស្សឯទៀត)។ ជាញឹកញាប់ សកម្មភាពអ្វីមួយក៏ដោយដែលកុមារធ្វើ តែងរួមបញ្ចូលបំណិនមួយពីផ្នែកចំបងនីមួយៗ។ ឧទាហរណ៍ នៅពេលកុមារលើកដៃឱ្យព គេកំពុងប្រើ :

- បំណិនកាយសម្បទា - កុមារលើកដៃឡើងលើ។
- បំណិនគំនិតបញ្ញា - កុមារស្គាល់អ្នក។
- ការប្រាស្រ័យទាក់ទង - កុមារប្រាប់អ្នកនូវអ្វីដែលគេចង់បាន។
- បំណិនសង្គម - កុមាររីករាយនឹងការដែលអ្នកលើកគេព។



តារាងនៅក្នុងជំពូកនេះ បង្ហាញបំណិនខ្លះដែលកុមាររៀន និងវ័យដែលកុមារភាគច្រើនរៀនបំណិនទាំងនោះ។ អ្នកអាចប្រើតារាងដើម្បីទទួលបានព័ត៌មានទូទៅ អំពីរបៀបដែលកុមារអភិវឌ្ឍ និងដើម្បីជួយអ្នកសំរេចចិត្តយកបំណិនអ្វីខ្លះដែលកូនអ្នកត្រូវការរៀន។




**តារាងបង្ហាញពីរបៀបដែលបំណិនកាយសម្បទារបស់កុមារប្រែប្រួល នៅពេលកុមារធំលូតលាស់។**

### ▶ របៀបដឹងពីបំណិនអ្វីខ្លះដែលកូនអ្នកត្រូវការរៀន

ចូររកតារាងសំរាប់ក្រុមអាយុជិតស្មើនឹងវ័យកូនអ្នក។ លើតារាង ចូរគូសរង្វង់មូលត្រង់បំណិនដែលកូនចេះហើយ។ អ្នកអាចរកឃើញថា កូនអ្នកមិនទាន់ចេះបំណិនមួយចំនួន ដែលកុមារឯទៀតមានវ័យស្រករនឹងកូនអ្នកចេះរួចហើយ។ ការដឹងបែបនេះ អាចជួយឱ្យអ្នកសំរេចចិត្តថា តើសកម្មភាពណាមួយដែលអ្នកចង់អនុវត្តជាមួយកូន។

**បើសិនជាការអភិវឌ្ឍរបស់កូនអ្នក មានការយឺតយ៉ាវជាងកុមារឯទៀតដែលមានអាយុស្រករគ្នា**

វាគឺជាការសំខាន់ដើម្បីធ្វើការលើបំណិនដែលកូនអ្នកត្រូវការរៀន**បន្ទាប់ទៀត** បើទោះជាបំណិនទាំងនោះ ជាបំណិនដែលកុមារឯទៀត តាមធម្មតារៀនតាំងពីអាយុនៅតិចក្តី។ នៅពេលកូនអ្នកចេះស្ទាត់ជំនាញនូវបំណិនមូលដ្ឋានកាន់តែច្រើន គេនឹងអាចរៀនបំណិនដែលកុមារមានវ័យស្រករគ្នាឯទៀតកំពុងរៀនអញ្ចឹងដែរ។ ការព្យាយាមបង្រៀនបំណិនមួយដល់កុមារ មុនពេលក្មេងត្រៀមខ្លួនដើម្បីរៀន វាបណ្តាលឱ្យមានការតឹងតែងចំពោះអ្នកទាំងពីរ។




ក្នុងតារាងខាងលើ ម្តាយក្មេងម្នាក់បានគូសរង្វង់ជុំវិញបំណិនដែលកូនស្រីអាយុ20ខែរបស់គាត់អាចធ្វើបាន។ កូនស្រីគាត់ត្រូវការជួយបន្ថែមទៀតដើម្បីចេះបំណិនក្នុងផ្នែកនីមួយៗ។ ប៉ុន្តែផ្នែកសំខាន់បំផុតដែលនាងត្រូវការឱ្យជួយ គឺត្រង់ផ្នែកការប្រាស្រ័យទាក់ទង និងផ្នែកគំនិតបញ្ញា។ ចំពោះកុមារវ័យតិចបែបនេះ ក្រុមគ្រួសារគួរតែធ្វើការលើមូលដ្ឋានការប្រាស្រ័យទាក់ទង (ជំពូកទី4) និងចាប់ផ្តើមណែនាំអំពីភាសា។

ចំពោះកុមារធំជាងនេះ អ្នកអាចចាប់ផ្តើមដោយពិនិត្យមើលតារាងដែលមានវ័យជិតស្មើនឹងកូនអ្នក។ អ្នកប្រហែលជាត្រូវពិនិត្យមើលតារាងសំរាប់កុមារអាយុតិច ដើម្បីឱ្យឃើញបំណិនដែលកូនអាចធ្វើបាន។ តារាងផ្សេងៗទៀតអាចផ្តល់គំនិតឱ្យអ្នកនូវប្រភេទនៃបំណិនដែលកូនអ្នកត្រូវការរៀន មុនពេលគេអាចធ្វើការលើបំណិនការសិក្សា ដូចបំណិនក្នុងតារាងដែលជិតស្មើនឹងវ័យរបស់គេ។

បើសិនជាកូនអ្នកមិនអាចស្តាប់ឮល្អ គឺកូនអ្នកពិតជាត្រូវការជួយជ្រោមជ្រែងបន្ថែមដើម្បីអភិវឌ្ឍបំណិនប្រាស្រ័យទាក់ទង គំនិតបញ្ញា និងសង្គម។ ជំពូកទី2 និងទី3 នឹងមានប្រយោជន៍ពីព្រោះពួកវាពន្យល់នូវរបៀបដែលកុមាររៀនភាសា និងផ្តល់ឱ្យជាគន្លឹះចំពោះរបៀបធ្វើការជាមួយកុមារតូច។ ពីព្រោះបំណិនគំនិតបញ្ញារបស់កុមារលូតលាស់ទន្ទឹមគ្នានឹងបំណិនប្រាស្រ័យទាក់ទងរបស់ពួកគេ សកម្មភាពក្នុងជំពូកទី4 ទី7 ទី8 និងទី9 នឹងជួយក្មេងឱ្យបង្កើនការអភិវឌ្ឍទាំងការប្រាស្រ័យទាក់ទង និងគំនិតបញ្ញា។ ជំពូកទី12 ស្តីពីបំណិនសង្គមបានផ្តល់យោបល់តាមវិធីជាច្រើន ដែលអ្នកអាចជួយកូនអភិវឌ្ឍសកម្មភាពទំនាក់ទំនងនៃសង្គមរបស់គេ។

ចំណែកនីមួយៗនៃរង្វង់នេះ បង្ហាញផ្នែកខុសៗគ្នានៃការអភិវឌ្ឍ ។ រូបភាព និងពាក្យ គឺជាឧទាហរណ៍នៃបំណិនដែលទារកជាច្រើនតែងចេះ នៅពេលពួកគេមាន**អាយុ3ខែ** ។




ទារកថ្លង់ ឬមិនអាចស្តាប់ឮល្អនឹងបានប្រយោជន៍ពីសកម្មភាពនានាដែលជួយពួកគេអភិវឌ្ឍនៅគ្រប់បំណិនក្នុងផ្នែកនីមួយៗ ។ រូបភាពខាងលើ គឺជា**ឧទាហរណ៍**នៃបំណិននានាតែប៉ុណ្ណោះ ។ នៅក្នុងឧទាហរណ៍ទាំងនេះ ចូរពិនិត្យមើលផ្នែក**"ការប្រាស្រ័យទាក់ទង"**នៃរង្វង់មូល: អ្នកមិនចាំបាច់ផ្លុំខ្លុយនោះទេ! សំណួរដែលអ្នកត្រូវសួរខ្លួនឯងគឺ បើសិនជាកូនមានប្រតិកម្មតបវិញភ្លាមទៅសម្លេង ឬក៏ចលនា ។

**ចូរចងចាំក្នុងចិត្តថា គោលបំណងគឺដើម្បីទារករបស់អ្នកធ្វើសកម្មភាពទាំងឡាយណាដែលទារកឯទៀតមានវ័យស្មើនឹងកូនអ្នកចេះធ្វើអញ្ចឹងដែរ នៅក្នុងសហគមន៍របស់អ្នក ។**

ចំណែកនីមួយៗនៃរង្វង់នេះ បង្ហាញផ្នែកខុសៗគ្នានៃការអភិវឌ្ឍ ។ រូបភាព និងពាក្យ គឺជាឧទាហរណ៍នៃបំណិនដែលទារកជាច្រើនតែងចេះ នៅពេលពួកគេមាន**អាយុ6ខែ** ។




ទារកថ្លង់ ឬមិនអាចស្តាប់ឮល្អនឹងបានប្រយោជន៍ពីសកម្មភាពនានាដែលជួយពួកគេអភិវឌ្ឍនៅគ្រប់បំណិនក្នុងផ្នែកនីមួយៗ ។ រូបភាពខាងលើ គឺជា**ឧទាហរណ៍**នៃបំណិននានាតែប៉ុណ្ណោះ ។ នៅក្នុងឧទាហរណ៍ទាំងនេះ ចូរពិនិត្យមើលផ្នែក"**កាយសម្បទា**"នៃរង្វង់មូលៈ ទារករបស់អ្នកមិនចាំបាច់លេងតែជាមួយចង្រ្កង់នោះទេ! សំណួរដែលអ្នកត្រូវសួរខ្លួនឯងគឺ បើសិនជាទារករបស់អ្នកធ្វើចលនាខ្ញើកៗ និងទធាក់ ដៃជើង ។

**ចូរចងចាំក្នុងគំនិតថា គោលបំណងគឺដើម្បីទារករបស់អ្នកធ្វើសកម្មភាពទាំងឡាយណា ដែលទារកឯទៀតមានវ័យស្មើនឹងកូនអ្នកធ្វើដូច្នេះដែរ នៅក្នុងសហគមន៍របស់អ្នក ។**

ចំណែកនីមួយៗនៃរង្វង់នេះ បង្ហាញផ្នែកខុសៗគ្នានៃការអភិវឌ្ឍ ។ រូបភាព និងពាក្យ គឺជាឧទាហរណ៍នៃបំណិនដែលកុមារជាច្រើនតែងចេះ នៅពេលពួកគេមាន**អាយុ12ខែ** ។




កុមារថ្លង់ ឬមិនអាចស្តាប់ឮល្អនឹងបានប្រយោជន៍ពីសកម្មភាពនានាដែលជួយពួកគេអភិវឌ្ឍនៅគ្រប់បំណិនក្នុងផ្នែកនីមួយៗ ។ រូបភាពខាងលើ គឺជា**ឧទាហរណ៍**នៃបំណិននានាតែប៉ុណ្ណោះ ។ នៅក្នុងឧទាហរណ៍ទាំងនេះ ចូរពិនិត្យមើលផ្នែក"**សង្គម**"នៃរង្វង់មូលៈ អ្នកមិនចាំបាច់លេងល្បែង វូម-វ៉ះ-អើ នោះទេ! សំណួរដែលអ្នកត្រូវសួរខ្លួនឯងគឺ បើសិនជាទារករបស់អ្នករីករាយលេងល្បែងកំសាន្តនៃសង្គម ។

**ចូរចងចាំក្នុងគំនិតថា គោលបំណងគឺដើម្បីកូនអ្នកធ្វើសកម្មភាពទាំងឡាយណា ដែលកុមារឯទៀតមានវ័យស្មើនឹងកូនអ្នកធ្វើដូច្នេះដែរ នៅក្នុងសហគមន៍របស់អ្នក ។**

ចំណែកនីមួយៗនៃរង្វង់នេះ បង្ហាញផ្នែកខុសៗគ្នានៃការអភិវឌ្ឍ ។ រូបភាព និងពាក្យ គឺជាឧទាហរណ៍នៃបំណិនដែលកុមារជាច្រើនតែងចេះ នៅពេលពួកគេមាន**អាយុ 2ឆ្នាំ**។




កុមារថ្លង់ ឬមិនអាចស្តាប់ឮល្អនឹងបានប្រយោជន៍ពីសកម្មភាពនានាដែលជួយពួកគេអភិវឌ្ឍនៅគ្រប់បំណិនក្នុងផ្នែកនីមួយៗ។ រូបភាពខាងលើ គឺជា**ឧទាហរណ៍**នៃបំណិននានាតែប៉ុណ្ណោះ។ នៅក្នុងឧទាហរណ៍ទាំងនេះ ចូរពិនិត្យមើលផ្នែក"**គំនិតបញ្ញា**"នៃរង្វង់មូលៈ កូនរបស់អ្នកមិនចាំបាច់ទាល់តែចេះវាយស្គរនោះទេ! សំណួរដែលអ្នកត្រូវសួរខ្លួនឯងគឺ បើសិនជាកូនរបស់អ្នកប្រើវត្ថុពីររួមគ្នា ។

**ចូរចងចាំក្នុងគំនិតថា គោលបំណងគឺដើម្បីកូនអ្នកធ្វើសកម្មភាពទាំងឡាយណា ដែលកុមារឯទៀតមានវ័យស្មើនឹងកូនអ្នកធ្វើដូច្នេះដែរ នៅក្នុងសហគមន៍របស់អ្នក។**

ចំណែកនីមួយៗនៃរង្វង់នេះ បង្ហាញផ្នែកខុសៗគ្នានៃការអភិវឌ្ឍ ។ រូបភាព និងពាក្យ គឺជាឧទាហរណ៍នៃបំណិនដែលកុមារជាច្រើនតែងចេះនៅពេលពួកគេមាន**អាយុ 3ឆ្នាំ** ។




កុមារថ្លង់ ឬមិនអាចស្តាប់ឮល្អនឹងបានប្រយោជន៍ពីសកម្មភាពនានាដែលជួយពួកគេអភិវឌ្ឍនៅគ្រប់បំណិនក្នុងផ្នែកនីមួយៗ ។ រូបភាពខាងលើ គឺជា**ឧទាហរណ៍**នៃបំណិននានាតែប៉ុណ្ណោះ ។ នៅក្នុងឧទាហរណ៍ទាំងនេះ ចូរពិនិត្យមើលផ្នែក **"សង្គម"** នៃរង្វង់មូលៈ កូនរបស់អ្នកមិនចាំបាច់ចេះជូតឥដ្ឋនោះទេ! សំណួរដែលអ្នកត្រូវសួរខ្លួនឯងគឺ បើសិនជាកូនរបស់អ្នករីករាយជួយធ្វើកិច្ចការជាមួយគ្រួសារ ។

**ចូរចងចាំក្នុងគំនិតថា គោលបំណងគឺដើម្បីកូនអ្នកធ្វើសកម្មភាពទាំងឡាយណាដែលកុមារឯទៀតមានវ័យស្មើនឹងកូនអ្នកធ្វើដូច្នេះដែរ នៅក្នុងសហគមន៍របស់អ្នក ។**

ចំណែកនីមួយៗនៃរង្វង់នេះ បង្ហាញផ្នែកខុសៗគ្នានៃការអភិវឌ្ឍ ។ រូបភាព និងពាក្យ គឺជាឧទាហរណ៍នៃបំណិនដែលកុមារជាច្រើនតែងចេះ នៅពេលពួកគេមាន**អាយុ 5ឆ្នាំ** ។




កុមារថ្លង់ ឬមិនអាចស្តាប់ឮល្អនឹងបានប្រយោជន៍ពីសកម្មភាពនានាដែលជួយពួកគេអភិវឌ្ឍនៅគ្រប់បំណិនក្នុងផ្នែកនីមួយៗ ។ រូបភាពខាងលើ គឺជា**ឧទាហរណ៍**នៃបំណិននានាតែប៉ុណ្ណោះ ។ នៅក្នុងឧទាហរណ៍ទាំងនេះ ចូរពិនិត្យមើលផ្នែក **"សង្គម"** នៃរង្វង់មូលៈ កូនរបស់អ្នកមិនចាំបាច់ផ្តោតអារម្មណ៍ចំពោះគ្រូបង្រៀននោះទេ! សំណួរដែលអ្នកត្រូវសួរខ្លួនឯងគឺ បើសិនជាកូនរបស់អ្នកយល់វិន័យដូចកុមារឯទៀត ។

**ចូរចងចាំក្នុងគំនិតថា គោលបំណងគឺដើម្បីកូនអ្នកធ្វើសកម្មភាពទាំងឡាយណាដែលកុមារឯទៀតមានវ័យស្មើនឹងកូនអ្នកធ្វើដូច្នេះដែរ នៅក្នុងសហគមន៍របស់អ្នក ។**